ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚

តុលាការកំពូល

សាលាដំបូងក្រុងភ្នំពេញ

ឃុំខ្លួនទៀងក្រុងភ្នំពេញ

លេខ : ៣៨

ចុះថ្ងៃទី០៥ - ៨ - ៩៨

សាលដីកា

លេខ : ២៨

ចុះថ្ងៃទី៨ - ៩ - ៩៩

## ពាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

ក្នុងបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្តី ប្រធាន
២ - លោក ឈឹម ស៊ីផល ចៅក្រម
៣ - លោក ប្រាក់ គីមសាន ចៅក្រម
៤ - លោក យស់ សួខៀន ចៅក្រម
៥ - លោក សោម សិរីវឌ្ឍ ចៅក្រមបម្រុងការ ... (ពុំច្បាស់)

លោក ប៉ុល វណ្ណា ក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ២៤ ចុះថ្ងៃទី០៥ - ៦ - ៩៨ របស់លោក - ឌីក សារឿន ដែលប្តឹងមិនសុខចិត្តពីសាលដីកាក្រុងភ្នំពេញលេខ ៧៤ ចុះថ្ងៃទី១០ - ៤ - ៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីបើកចោទមួយ និងឃុំខ្លួនទៀងក្រុងភ្នំពេញលេខ ៣៨ ចុះថ្ងៃទី០៥ - ៨ - ៩៨ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ ទេព តិច " ចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មុខរបរ លក់ដូរ ទីលំនៅភូមិ២០ឧសភា ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបាត់ដំបង ឪពុកឈ្មោះ ទេព - ផេង " ស " ម្តាយឈ្មោះ ចេីន ថែម " រស់ " ប្រពន្ធឈ្មោះស៊ីវ ខេង មានកូន០៤នាក់

ត្រូវចោទពីបទ : បរិហារកេរ្តិ៍ ប្រព្រឹត្តនៅលើទឹកដីខេត្តបាត់ដំបង កាលពីថ្ងៃទី២៥ - ១០ - ៩៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

មេធាវី គ្មាន

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ១ - មុំ ក្រាត "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស

អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរអនុប្រធានមន្ទីរទំនប់ធំ ទីលំនៅសព្វថ្ងៃនៅឃុំ - ស្រុកស្វាយទៀប ខេត្តកំពង់ចាម ។

២- ឈ្មោះ ម៉ែន ចុង "ខ្លាចស្ដីងសាទុក្ខ" ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរប្រធានការិយាល័យវិទ្យុ ទូរទស្សន៍ខេត្ត ទីលំនៅសព្វថ្ងៃឃុំសំរោង ស្រុកឯកភ្នំ ខេត្តកំពង់ចាម ។

៣- ឈ្មោះ ផឹក សារឿន "ខ្លាចស្ដីងសាទុក្ខ" ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរអនុប្រធានការិយាល័យវិទ្យុ ទូរទស្សន៍ខេត្ត ទីលំនៅសព្វថ្ងៃភូមិ... ឃុំ-ស្រុកស្វាយទៀប ខេត្តកំពង់ចាម ។

មេធាវី គ្មាន

- តាមពាក្យប្ដឹងចុះថ្ងៃទី២០-១០-៩៤ របស់ឈ្មោះ ទេព តិច ប្ដឹងចុះ លើទំព័រ កាសែតសេដ្ឋកិច្ច ។ ក្រោយពីការស៊ើបអង្កេតរួចឃាត់ឈ្មោះ មុំ ក្រាត - ម៉ែន ចុង - ផឹក សារឿន កើតទុក្ខចិត្តក៏កើតរឿងប្ដឹងខ្ទារ៉ែតដូង ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាការខេត្តកំពង់ចាម ថា៖

១- ចោទប្រកាន់លើឈ្មោះ ទេព តិច ពីបទបរិហារកេរ្តិ៍ តាមទំព័រកាសែតសេដ្ឋកិច្ច កាលពីថ្ងៃទី២៩-១០-៩៤ ។ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- បញ្ជូនសំណុំរឿង និងបញ្ជីរាយនាមជនជាប់ចោទ ទៅតុលាការដើម្បីចាត់ការតាមច្បាប់ ។

- បានឃើញដីកាក្រមព្រហ្មទណ្ឌលេខ...ចុះថ្ងៃទី ១៦-១១-៩៤ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារសេចក្ដីសំរេចដូចតទៅ ៖

១- ផ្តន្ទាទោសដាក់ពិន័យជាប្រាក់ លើឈ្មោះ ទេព តិច ភេទប្រុស អាយុ៥០ឆ្នាំ ចំនួន ១.០០០.០០០ រៀល ពីបទបរិហារកេរ្តិ៍ ប្រព្រឹត្តនៅលើទំព័រកាសែតសេដ្ឋកិច្ច កាលពីថ្ងៃទី២៩-១០-៩៤ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- បង្គាប់អោយឈ្មោះ ទេព តិច សងសំណងជម្ងឺចិត្តអោយដល់ឈ្មោះ មុំ ក្រាត - ម៉ែន ចុង - ផឹក សារឿន សរុបចំនួន ២.០០០.០០០ រៀល ។ ដើម្បីផ្តល់សំណងរដ្ឋប្បវេណី ទាមទារដើមពីនេះបង់ហេតុទៅលើ ។ ក្នុងករណីឈ្មោះ ទេព តិច គ្មានប្រាក់សងជម្ងឺ និង ប្រាក់ពិន័យគ្រប់ចំនួនទេនោះ ត្រូវដាក់គុកបង្ខំលើរូបកាយ ដើម្បីទារប្រាក់សំណង និងប្រាក់ពិន័យតាម...ឆ្នាំតាមមាត្រា...នៃច្បាប់ស្ដីពីការដាក់គុកបង្ខំលើរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ...ក្រចុះថ្ងៃទី ០៨-០២-៨៦ ។

៤- អោយប្រកែននេះជំនុំជំរះ និងប្រកាសសាលក្រមនេះ ចំពោះមុខជនជាប់ចោទ

និង ដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងឧទ្ធរណ៍នេះវិញ និងចាប់តាំងពីថ្ងៃ កាត់សេចក្ដីនេះតទៅ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី០៣-០១-៩៦ របស់ឈ្មោះទេព តិច ដែលប្ដឹងមិនសុខចិត្តពីសាលក្រមលេខ ៣៦៦ ចុះថ្ងៃទី១៨-១១-៩៥ របស់តុលាការខេត្តបាត់ដំបង ប្រឆាំងចំនុចទាំងស្រុងនៃសាលក្រម ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា ៖ តាមគំនិតរបស់អគ្គព្រះរាជអាជ្ញាសុំអោយធ្វើការអង្កេតលើរឿងនេះឡើងវិញ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៧៤ ចុះថ្ងៃទី១០-៤-៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសេចក្ដីសំរេចដូចតទៅ ៖

១- ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៣-០១-៩៦ របស់ជនជាប់ចោទឈ្មោះទេព តិច ទុកជាត្រឹមត្រូវតាមទំរង់ និងនីតិច្បាប់ ។

២- បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ៣៦៦ ចុះថ្ងៃទី១៨-១១-៩៥ របស់តុលាការខេត្តបាត់ដំបងចោលជាអសារបង់ ។

៣- អោយឈ្មោះទេព តិច រួចខ្លួនពីបទចោទបរិហារកេរ្តិ៍ ប្រព្រឹត្តនៅលើទំព័រកាសែតសេដ្ឋកិច្ច កាលពីថ្ងៃទី២៨-១០-៩៤ ។

៤- សាលដីកានេះជំនុំជំរះជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី០៥-៦-៩៨ របស់ឈ្មោះធីក សារឿន តំណាងអោយ លោកមុំ ក្រាត - កែវ ហុង ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៧៤ ចុះថ្ងៃទី ១០-៤-៩៨ របស់សាលាឧទ្ធរណ៍ លើសាលដីកានេះទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី១៦-១០-៩៨ របស់ឈ្មោះធីក សារឿន - មុំ ក្រាត - កែវ ហុង " ម្ចាស់បណ្ដឹងសាទុក្ខ " ។

- បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី៣០-១១-៩៨ របស់ឈ្មោះទេព តិច " - " ចុងបណ្ដឹងសាទុក្ខ "

- បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ថា ៖

- បណ្ដឹងសាទុក្ខរបស់ឈ្មោះធីក សារឿន ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីបករឿងនេះមកពិនិត្យ ពិចារណា ។

- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៧៤ ចុះថ្ងៃទី១០-៤-៩៨ ទុកជាបានការ ។

- បានស្ដាប់ចម្លើយរបស់ជនជាប់ចោទ ខ្លួនសុំអោយតុលាការកំពូលមេត្តាជួយតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការផងចុះ ។

- ចូលស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថា ខ្លួនពុំដែលបានលក់អ្វីដែលជាទ្រព្យសម្បត្តិ របស់រដ្ឋបន្តិចណាទើបយមូលហេតុអ្វីបានជាឈ្មោះទេព តិចម៉ាននិយាយបរិហារកេរ្តិ៍ ថែមទាំងចុះកាសែត ថែមទៀត ។

- ចូលស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ ថា សូមរក្សាសេចក្តីសន្និដ្ឋាន នៅដដែល ។

- ក្រោយពីចូលស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីចូលស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីចូលស្តាប់ចម្លើយដោះសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និង របស់ជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- ឃើញថាបណ្តឹងសាទុក្ខលេខ ២៥ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩៨ របស់លោក ជឹក សាធឿន តំណាងមេធាវីលោកប៉ុំ ក្រាត-លោកកែវ ហ៊ុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា២៥ នៃច្បាប់ស្តីពីការរៀបតាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- ឃើញថាអង្គហេតុដែលចុះក្នុងកាសែតសេដ្ឋកិច្ចនោះគឺជាពាក្យបណ្តឹងរបស់លោក ទេព និច ទៅតុលាការ ។ ប៉ុន្តែកាសែតសេដ្ឋកិច្ចបានសរសេរ ឱ្យចំណងជើងបន្ថែម ដែលមាន លក្ខណៈជាការបរិហារកេរ្តិ៍ទៅវិញ ។

- ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ៣៥ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៨ របស់សាលា ឧទ្ធរណ៍ដែលបានតំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងអង្គច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីជំរះមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ.

១ - ទទួលបណ្តឹងសាទុក្ខលេខ២៥ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩៨ របស់លោកជឹក សាធឿន ទុកថាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងអង្គច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៣៥ ចុះថ្ងៃទី២០ខែមេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងស្រុង ។

៣ - សាលដីកានេះប្រកាសជាសាធារណៈនាសាលាសវនាការ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៨